# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៥ សសរ

## សេចក្តីសម្រេច

### ស្តីពី

### ការបង្កើតក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រង

### គំរោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា

៣៣៕៧៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងយុត្តិធម៌
- យោងអនុស្សារណៈយោគយល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤
- យោងអនុស្សារណៈ ស្តីពី ការរៀបចំចាត់ចែង ទាក់ទងនឹងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាល ទី៣ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០០៧
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**ប្រការ១ :** បង្កើតក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី៣ ដែលរួមមាន គណកម្មការប្រតិបត្តិ លេខាធិការដ្ឋាន និងក្រុមពិគ្រោះ យោបល់ ។ ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងនេះដឹកនាំដោយ :

១-ឯកឧត្តម **ប្រាំ សុខា** ប្រធាន

២-ឯកឧត្តម **អ៊ី ជន** អនុប្រធាន

៣-ឯកឧត្តម **ស៊ុយ ម៉ុងឈាង** អនុប្រធាន

**ប្រការ២ :** គណកម្មការប្រតិបត្តិនៃក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងព្រហ្មទណ្ឌយុត្តិធម៌មានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- | ឯកឧត្តម **ប្រាំ សុខា**, រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ. | ប្រធាន |
| ២- | ឯកឧត្តម **អ៊ី ជន**, រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌. | អនុប្រធាន |
| ៣- | ឯកឧត្តម **ស៊ុយ ម៉ុងឈាង**, ប្រធានអង្គភាពគ្រប់គ្រងគំរោង នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌. | អនុប្រធាន |
| ៤- | ឯកឧត្តម **គេង សាវឌ្ឍ**, អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន. | សមាជិក |
| ៥- | ឯកឧត្តម **អ៊ិត រ៉ាឌី**, អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌. | សមាជិក |
| ៦- | ឯកឧត្តម **ឃឹម បូរ**, អភិបាល ខេត្តកណ្តាល. | សមាជិក |
| ៧- | ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហេង ហាក់**, អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ. | សមាជិក |
| ៨- | ឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ៅ ចំនួតារា**, អគ្គស្នងការរងនគរបាលជាតិ ក្រសួងមហាផ្ទៃ. | សមាជិក |
| ៩- | ឯកឧត្តម **ខៀង ទី**, អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ. | សមាជិក |
| ១០- | តំណាងភ្នាក់ងារអូស្ត្រាលីដើម្បីការអភិវឌ្ឍន៍អន្តរជាតិ (AusAID), ស្ថានទូតអូស្ត្រាលី | សមាជិក |
| ១១- | តំណាងក្រុមហ៊ុន Global Justice Solutions (ក្រុមហ៊ុនទទួលការគំរោង CCJAP III ) | សមាជិក |
| ១២- | តំណាងប៉ូលីសសហព័ន្ធអូស្ត្រាលី (AFP) | សមាជិក |
| ១៣- | តំណាងមួយរូប នៃដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍នានា | សមាជិក |

ក្នុងករណីចាំបាច់ និងដោយមានការឯកភាពពីគណកម្មការប្រតិបត្តិ ប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោង អាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន ឬអ្នកពាក់ព័ន្ធផ្សេងៗទៀត មកចូលរួមក្នុងគណកម្មការប្រតិបត្តិ នៅពេលណាមួយក៏បាន។

**ប្រការ៣** : គណៈកម្មការប្រតិបត្តិមានភារកិច្ចដូចតទៅ :

- ពិនិត្យតាមដានលើការអនុវត្តន៍ តាមរយៈផែនការការងារប្រចាំឆ្នាំ របាយការណ៍ស្តីពីការវិវឌ្ឍន៍របស់គំរោង និងរបាយការណ៍របស់ក្រុមប្រឹក្សាបច្ចេកទេស។
- ពិនិត្យតាមដានការវាយតំលៃលើការចំណាយក្នុងផែនការការងារប្រចាំឆ្នាំ ប្រៀបធៀបនឹងការបែងចែកថវិកាឆ្នាំសារពើពន្ធ (ដែលអង្គការ AusAID ផ្តល់អោយ បន្ទាប់ពីដំណើរការការងារថវិកាប្រចាំឆ្នាំ នៅខែឧសភា) ហើយធានាថា ផែនការការងារប្រចាំឆ្នាំ ត្រូវបានគ្រោងរៀបចំត្រឹមត្រូវ ដើម្បីឆ្លុះបញ្ចាំងពីថវិកាដែលមាន។
- ធ្វើការបែងចែកធនធានជាយុទ្ធសាស្ត្រ ទៅតាមបណ្តាផ្នែកទាំងអស់របស់គំរោង។
- កំណត់ និងសំរេចពីលក្ខណៈវិនិច្ឆ័យលើការបែងចែកថវិការបស់មូលនិធិគាំទ្រ (Flexible Support Fund) ទៅអោយផ្នែកនិមួយៗរបស់គំរោង និងសកម្មភាពគាំទ្រដល់ការងារសាងសង់។
- ជូនដំណឹងដល់រដ្ឋាភិបាលទាំងពីរ អំពីដំណើរការវិវឌ្ឍន៍របស់គំរោង និងលើកអនុសាសន៍ជូនរដ្ឋាភិបាលទាំងពីរអំពីការប្រែប្រួលក្នុងផ្នែកនានារបស់គំរោង និងអំពីទិសដៅអនាគត។
- ពិនិត្យតាមដានសកម្មភាពផ្សេងៗទៀត ដើម្បីធានាបានថា ធនធានរបស់គំរោងមិនត្រូវបានប្រើប្រាស់ត្រួតគ្នាទៅនឹងធនធានរបស់អ្នកផ្តល់ជំនួយផ្សេងៗទៀត។
- លើកទឹកចិត្តដល់ដៃគូពាក់ព័ន្ធដទៃទៀត អោយប្រើប្រាស់យន្តការរបស់គំរោង ដើម្បីផ្តល់ជំនួយមូលនិធិ និងផ្តល់ជំនួយដែលទាក់ទងនឹងការកំណត់របស់គំរោង។ ប្រសិនបើមានការយល់ឃើញថា អាចអនុញ្ញាតិអោយមានការចូលរួមរបស់ដៃគូអ្នកផ្តល់ជំនួយ គណៈកម្មការប្រតិបត្តិត្រូវពិចារណាអំពីការអញ្ជើញដៃគូអ្នកផ្តល់ជំនួយនោះ ចូលជាសមាជិករបស់ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោង។

**ប្រការ៤** : លេខាធិការដ្ឋាន នៃក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោង មានសមាសភាពដូចខាងក្រោម:

១- លោក Larry Proud, ប្រធានគំរោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា ប្រធាន

២- មន្ត្រីគំរោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា សមាជិក

៣- ជនបង្គោល សមាជិក

**ប្រការ៥** : លេខាធិការដ្ឋានមានភារកិច្ចដូចខាងក្រោម :

- ជាសេនាធិការឱ្យក្រុមប្រឹក្សាជាតិគ្រប់គ្រងគំរោង។
- រៀបចំចាត់ចែងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោង។
- រៀបចំចាត់ចែងរបៀបវារៈអង្គប្រជុំ របាយការណ៍សង្ខេបអំពីបញ្ហាសំខាន់ៗ សំរាប់ជាពត៌មាន និងសំរាប់ការពិចារណារបស់ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោង។
- ធ្វើការកត់ត្រាក្នុងអង្គប្រជុំ និងចែកជូនកំណត់ហេតុ និងលទ្ធផលកិច្ចប្រជុំ។

**ប្រការ៦** : ក្រុមពិគ្រោះយោបល់ នៃក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងមានសមាសភាពដូចខាងក្រោម :

១- លោកឧត្តមសេនីយ៍ **នួន ឫទ្ធិល** អនុប្រធាននាយកដ្ឋានកណ្តាល នគរបាលយុត្តិធម៌ ក្រសួងមហាផ្ទៃ (ជនបង្គោល ផ្នែក ទបសស) ប្រធាន

២- ឯកឧត្តម ឧត្តមសេនីយ៍ **ម៉ា ឈឿន** អនុប្រធានអចិន្ត្រៃយ៍សាលាភូមិន្ទនគរបាល និងជាប្រធាន នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ក្រសួងមហាផ្ទៃ សមាជិក

៣- ឯកឧត្តម ឧត្តមសេនីយ៍ **ចាន់ អ៊ាន** ប្រធាននាយកដ្ឋានបុគ្គលិក ក្រសួងមហាផ្ទៃ. សមាជិក

៤- លោក ឧត្តមសេនីយ៍ **ខៅខ លឹម** ប្រធាននាយកដ្ឋានជនបរទេស ក្រសួងមហាផ្ទៃ សមាជិក

៥- ឯកឧត្តម **នេត ដារ៉ុខ** ប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សមាជិក

៦- ឯកឧត្តម **សួខ លាងហៃ** អនុប្រធានអង្គភាពគ្រប់គ្រងគំរោង នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ (ជនបង្គោល ផ្នែកគាំទ្រកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌) សមាជិក

៧- លោក **ឡាយ ណារ៉ុច** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ (ជនបង្គោល) សមាជិក

៨- លោក **គុយ ប៊ុនសន**. អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ (ជនបង្គោលផ្នែកពន្ធនាគារ) សមាជិក

៩- លោកឧត្តមសេនីយ៍ **គៀត ចន្ថារិទ្ធ** ប្រធានសេនាធិការដ្ឋាន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ជនបង្គោលផ្នែកនគរបាល) សមាជិក

១០- លោក **ចេង ញ៉ាន់** អភិបាលរង ខេត្តកណ្តាល និងជាប្រធានលេខាធិការដ្ឋាន ទបសស ខេត្ត (ជនបង្គោល ផ្នែក ទបសស ខេត្ត) សមាជិក

១១- លោក **តុង ពាវ** ប្រធាននាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ ក្រសួងយុត្តិធម៌ (ជនបង្គោល ផ្នែកក្រសួងយុត្តិធម៌ និងតុលាការ) សមាជិក

១២- លោក ឧត្តមសេនីយ៍ **ខណ្ណ រដ្ឋា** ប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ សមាជិក

១៣- លោកជំទាវ ឧត្តមសេនីយ៍ **អ៊ុន សុគន្ធា** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ សមាជិក

១៤- លោក **ខៀវ សារម៉េត** ប្រធានតុលាការ ខេត្តកណ្តាល សមាជិក

១៥- លោក **ហ៊ួត ឫទ្ធី** ព្រះរាជអាជ្ញាអមតុលាការ ខេត្តកណ្តាល សមាជិក

១៦- លោក **ទី គេង** អនុប្រធាននាយកដ្ឋានអប់រំកែប្រែ នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ សមាជិក

១៧- លោក **សុខ ឌឿន** អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សមាជិក

ដោយមានការឯកភាពពីគណកម្មការប្រតិបត្តិ ប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោង អាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន ឬអ្នកពាក់ព័ន្ធផ្សេងៗទៀត មកចូលរួមក្នុងក្រុមពិគ្រោះយោបល់ទៅតាមតំរូវការជាក់ស្តែង ។

**ប្រការ៧** : ក្រុមពិគ្រោះយោបល់មានភារកិច្ចដូចតទៅ :

- ផ្តល់អនុសាសន៍ និងជាជំនួយដល់គណកម្មការប្រតិបត្តិ ។
- ចូលរួមក្នុងអនុគណកម្មការនានា កាលបើចាំបាច់ត្រូវបង្កើត ។

**ប្រការ ៨** :ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងត្រូវជួបប្រជុំគ្នាយ៉ាងតិច២ដងក្នុងមួយឆ្នាំ ដើម្បីពិភាក្សា និងសំរេចលើរាល់ផែនការ គោលនយោបាយ និងសកម្មភាពអនុវត្តរបស់គំរោង ។

**ប្រការ ៩ :** ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងមានទីស្នាក់ការនៅក្រសួងមហាផ្ទៃ សំរាប់ធ្វើការងារប្រចាំថ្ងៃ និងមានសិទ្ធិប្រើប្រាស់មន្ត្រីរបស់ក្រសួងមហាផ្ទៃ, ក្រសួងយុត្តិធម៌, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលមានការងារជំនាញទាក់ទងនឹងគំរោង។

**ប្រការ ១០:** ក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ សំរាប់រាល់លិខិតផ្លូវការរបស់ខ្លួន។

**ប្រការ ១១ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ប្រការ២ ប្រការ៤ និងប្រការ៦ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃ ចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ខែ ឧសភា ឆ្នាំ២០០៧

ជ. នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ១-ប្រការ២-ប្រការ៤ និងប្រការ៦
- ឯកសារ-កាលប្បវត្តិ